# ព្រះរាជក្រម

នស/រកម/១០០៧/០២៦

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន ស្តីពីការជំរុញនិងការការពារវិនិយោគ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៧ នាសម័យប្រជុំវិសាមញ្ញរបស់រដ្ឋសភា នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៧ នាសម័យប្រជុំវិសាមញ្ញរបស់ព្រឹទ្ធសភា ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន ស្តីពីការជំរុញនិងការការពារវិនិយោគ

**មាត្រា ១.-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន ស្តីពីការជំរុញ និងការការពារវិនិយោគ ដែលធ្វើនៅរាជធានីភ្នំពេញ នាថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៤ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០០៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស.រកម.១០០៧.៥៣៤

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
**ហត្ថលេខា**
**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
**ហត្ថលេខា**
**គាត ឈន់**

លេខ: ៤៩៦ ចប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

**ឃុន ជិនកេន**

# កិច្ចព្រមព្រៀង
# រវាង
# រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
# និង
# រដ្ឋាភិបាលនៃសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន
# ស្តីពី
# ការជំរុញ និងការការពារវិនិយោគ

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថានចាប់ពីពេលនេះតទៅហៅថា " ភាគីនៃកិច្ចសន្យា"

ក្នុងគោលបំណងបង្កើតនូវលក្ខខ័ណ្ឌសមស្របសំរាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចដ៏ធំធេងរវាងភាគីទាំងពីរ និងជាពិសេស សំរាប់ការវិនិយោគនៃវិនិយោគិន នៃរដ្ឋមួយនៅលើទឹកដី នៃរដ្ឋមួយទៀត ដោយផ្អែកលើគោលការណ៍ ស្មើភាព និងមានផលប្រយោជន៍ទៅវិញទៅមក ។

ដោយទទួលស្គាល់ថា ការលើកទឹកចិត្ត និងការការពារទៅវិញទៅមកនៃការធ្វើវិនិយោគមានប្រយោជន៍ក្នុងការជំរុញការផ្តួចផ្តើមអាជីវកម្ម និងលើកស្ទួយភាពរុងរឿងនៃប្រទេសទាំងពីរ ។

ដោយព្រមព្រៀងថា របនាសម្ព័ន្ធដែលមានស្ថេរភាពសំរាប់វិនិយោគ នឹងបង្កើនការប្រើប្រាស់ធនធានសេដ្ឋកិច្ចអោយមានប្រសិទ្ធិភាព និងលើកស្ទួយភាពរុងរឿង ។

ដោយមានបំណងចុះនូវកិច្ចព្រមព្រៀងស្តីពីការជំរុញ និងការការពារទៅវិញទៅមកនៃវិនិយោគ បានព្រមព្រៀងគ្នាដូចតទៅ :

## មាត្រាទី ១

## និយមន័យ

គោលបំណងនៃកិច្ចព្រមព្រៀង ៖

១- ពាក្យ "វិនិយោគទុន" មានន័យថា

(ក) ទ្រព្យ ឬបរិយវត្ថុ ដែលវិនិយោគទាក់ទងជាមួយសកម្មភាពសេដ្ឋកិច្ចពាក់ព័ន្ធនឹងការធ្វើអាជីវកម្មរបស់អ្នកវិនិយោគនៃភាគីមួយ ធ្វើនៅលើទឹកដីនៃភាគីម្ខាងទៀតក្នុងការធ្វើការបង្កើត ការរៀបចំ ឬការគ្រប់គ្រងឧស្សាហកម្មពាក់ព័ន្ធនឹងការរៀបចំដំណើរការនៅក្នុងផលិតកម្ម ការចែកចាយ ឬការកែច្នៃនូវរាល់ទំនិញ ឬការបំរើសេវា និងការទាញយកផលធនធានរ៉ែ និងផលិតផលផ្សេងទៀតដូចមានបញ្ជាក់ថាមានប្រយោជន៍ដល់ភាគីជាប់កិច្ចសន្យា។

(ខ) "ពាក្យវិនិយោគ មិនរាប់បញ្ចូលផងទេនូវកិច្ចសន្យាក្នុងការផ្តល់សេវាកម្ម និងកិច្ចសន្យាសាងសង់។"

(គ) "សំរាប់ករណីកិច្ចសន្យារវាងនិវាសនជននៃភាគីជាប់កិច្ចសន្យាម្ខាង ជាមួយនិវាសនជននៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ខ្លឹមសារនិងលក្ខខណ្ឌនៃកិច្ចសន្យាដែលចុះហត្ថលេខារវាងភាគីនោះនឹងមិនមានពាក់ព័ន្ធជាមួយបទបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះទេ ហើយនឹងគ្រប់គ្រងដោយខ្លឹមសារ និងលក្ខខណ្ឌនៃកិច្ចសន្យានោះ ។"

(ឃ) កិច្ចសន្យាស្តីពីការកំណត់កាលបរិច្ឆេទ នឹងមិនអាចចាត់ទុកជាការវិនិយោគទេ ។

២- ពាក្យ "ផលចំណូល" មានន័យថា រូបិយវត្ថុបានមកពីការវិនិយោគ រួមមានប្រាក់ចំណេញ ណាមួយ ការប្រាក់ ផលកំរៃ ប្រាក់ចំណេញនៃភាគហ៊ុន កំរៃឈ្នួល ឬកំរៃ ។

៣- ពាក្យ "វិនិយោគិន" មានន័យចំពោះភាគីជាប់កិច្ចសន្យានិមួយៗ ៖

(ក) រូបវន្តបុគ្គលជាជនជាតិនៃភាគីជាប់កិច្ចសន្យាដែលធ្វើការវិនិយោគនៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ។

(ខ) នីតិបុគ្គលដែលបង្កើតឡើង ឬរៀបចំតាមរបៀបផ្សេងទៀតស្របតាមច្បាប់ និងបទបញ្ញត្តិ

នៃភាគីជាប់កិច្ចសន្យាម្ខាងមានទីស្នាក់ការ និងធ្វើសកម្មភាពជំនួញពិតប្រាកដនៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យានោះ ហើយបានធ្វើវិនិយោគនៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ។

៤- ពាក្យ "រូបិយវត្ថុងាយស្រួលផ្លាស់ប្តូរដោយសេរី" មានន័យថា រាល់រូបិយបណ្ណ ដែលអាចប្រើប្រាស់បានជាទូទៅសំរាប់ការទូទាត់ក្នុងអាជីវកម្មអន្តរជាតិ និងធ្វើពាណិជ្ជកម្មយ៉ាងទូលាយនៅក្នុងទីផ្សារប្តូរប្រាក់អន្តរជាតិសំខាន់ៗ ។

៥- ពាក្យ "ទឹកដី" មានន័យថា

- ចំពោះព្រះរាជាណាចក្រកម្ពុជា គឺទឹកដីដែលព្រះរាជាណាចក្រកម្ពុជា មានអធិបតេយ្យភាព ឬយុត្តាធិការ ។
- ចំពោះសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន គឺទឹកដីដូចដែលបានផ្តល់និយមន័យនៅក្នុងមាត្រា(១) និង (២) នៃរដ្ឋធម្មនុញ្ញរបស់សាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន ។

## មាត្រាទី ២
## ការជំរុញ និងការការពារវិនិយោគ

១- ភាគីនិមួយៗ ត្រូវលើកទឹកចិត្ត និងបង្កើតលក្ខខ័ណ្ឌសមស្របដល់វិនិយោគិននៃភាគីម្ខាងទៀតក្នុងការធ្វើវិនិយោគក្នុងទឹកដីរបស់ខ្លួន ហើយទទួលស្គាល់ការវិនិយោគនោះ ដោយអនុលោមតាមច្បាប់ និងបទបញ្ញត្តិរបស់ខ្លួន ។

២- ដើម្បីលើកទឹកចិត្តនូវលំហូរវិនិយោគទៅវិញទៅមក ភាគីនិមួយៗត្រូវខិតខំជូនដំណឹងទៅភាគីម្ខាងទៀត តាមសំណើនៃភាគីនោះនូវឱកាសវិនិយោគក្នុងទឹកដីរបស់ខ្លួន ។

៣- ភាគីនិមួយៗ ត្រូវធ្វើការពិចារណាជាបន្ទាន់ និងក្នុងគោលបំណងល្អ ក្នុងករណីចាំបាច់ស្របទៅតាមច្បាប់ និងបទបញ្ញត្តិរបស់ខ្លួននូវសំណើសុំការអនុញ្ញាតទាំងឡាយទាក់ទងទៅនឹងសកម្មភាពនៃទីប្រឹក្សា ឬអ្នកជំនាញការដែលតំរូវដោយវិនិយោគិននៃភាគីម្ខាងទៀត ។

៤- ភាគីនិមួយៗត្រូវអនុវត្តច្បាប់ បទបញ្ញត្តិ និងនីតិវិធីរបស់ខ្លួនទាក់ទងនឹងការចូល ការស្នាក់នៅ និងការបំរើការងារនៃរូបវន្តបុគ្គលដោយពិនិត្យឱ្យបានល្អ និងផ្តល់ការយកចិត្តទុកដាក់ចំពោះសំណើនៃ

បុគ្គលិកសំខាន់ៗ (ពលរដ្ឋនៃភាគី) រួមមានអ្នកគ្រប់គ្រងថ្នាក់ខ្ពស់ និងបុគ្គលិកបច្ចេកទេសដែលបំរើការអោយគោលបំណងនៃការវិនិយោគ ដើម្បីចូលមកស្នាក់នៅមួយរយៈ និងធ្វើការនៅក្នុងទឹកដីរបស់ខ្លួន។ សមាជិកគ្រួសារដែលជិតបំផុត (សហព័ទ្ធនិងកូនក្នុងបន្ទុក) នៃបុគ្គលិកសំខាន់ៗនោះត្រូវបានផ្តល់អោយដូចគ្នាចំពោះការចូល និងការស្នាក់នៅមួយរយៈក្នុងប្រទេសនៃភាគីម្ចាស់ផ្ទះ ។

## មាត្រានី ៣
## ការការពារវិនិយោគ

១- ភាគីនីមួយៗ ត្រូវបង្កើនក្នុងទឹកដីរបស់ខ្លួននូវកិច្ចការពារយ៉ាងពេញលេញ និងមានសុវត្ថិភាពចំពោះការវិនិយោគ និងផលចំណូលនៃវិនិយោគិនរបស់ភាគីជាប់កិច្ចសន្យាម្ខាងទៀត ។ គ្មានភាគីណាមួយត្រូវប្រឈមដោយវិធានការមិនសមហេតុផល ឬរើសអើងក្នុងការអភិវឌ្ឍន៍ ការគ្រប់គ្រង ការប្រើប្រាស់ ការអាស្រ័យផល ការពង្រីកការលក់ និងប្រសិនបើមាន សំរាប់ការជំរះបញ្ជីវិនិយោគឡើយ ។ ភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវពិនិត្យនូវបណ្តាកាតព្វកិច្ចផ្សេងៗដែលអាចមានទំនាក់ទំនងចំពោះការវិនិយោគរបស់វិនិយោគិន នៃភាគីម្ខាងទៀត ។

២- ការវិនិយោគ ឬផលចំណូលនៃប្រាក់ចំណេញរបស់វិនិយោគិននៃភាគីម្ខាងនៅលើទឹកដីនៃភាគីម្ខាងទៀត ត្រូវទទួលបាននូវសមភាព និងភាពស្របតាមច្បាប់ តាមបទបញ្ញត្តិនៃភាគីជាម្ចាស់ទឹកដីនោះ និងបទបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ.។

## មាត្រានី ៤
## ប្រព្រឹត្តិកម្មជាតិ និងប្រព្រឹត្តិកម្មនៃប្រជាជាតិដែលទទួលនូវការអនុគ្រោះបំផុត

១- ភាគីនីមួយៗ ត្រូវផ្តល់នូវការយល់ព្រមក្នុងទឹកដីរបស់ខ្លួនលើការធ្វើវិនិយោគ និងផលចំណូលរបស់វិនិយោគិននៃភាគីជាប់កិច្ចសន្យាម្ខាងទៀត នូវប្រព្រឹត្តិកិច្ចមិនតិចជាងអ្វីដែលខ្លួនបានផ្តល់អោយទៅវិនិយោគិន និងទិន្នផលរបស់វិនិយោគិនខ្លួននោះឡើយ ឬការវិនិយោគ និងទិន្នផល

របស់វិនិយោគិននៃរដ្ឋទីបីណាមួយក៏ដោយឱ្យតែប្រព្រឹត្តិកិច្ចនោះមានលក្ខណៈអនុគ្រោះច្រើនចំពោះវិនិយោគិនដែលពាក់ព័ន្ធ ។

២- ភាគីជាប់កិច្ចសន្យា ត្រូវផ្តល់ការយល់ព្រមក្នុងទឹកដីរបស់ខ្លួនទៅអោយវិនិយោគិននៃភាគីជាប់កិច្ចសន្យាម្ខាងទៀតទាក់ទងនឹងការគ្រប់គ្រង ការថែរក្សា ការផ្តល់ ឬការទទួលការងារ ការប្រើប្រាស់ ឬការចាត់ចែងនៃការវិនិយោគនូវប្រព្រឹត្តិកិច្ច មិនតិចជាងអ្វីដែលខ្លួនបានយល់ព្រមផ្តល់ជូនវិនិយោគិននៃរដ្ឋទីបីណាមួយ ។

៣- បណ្តាបញ្ញត្តិនៃវាក្យខ័ណ្ឌ ១ និង ២ នៃមាត្រានេះមិនត្រូវបានបកស្រាយដើម្បីតំរូវឱ្យភាគីជាប់កិច្ចសន្យាម្ខាងផ្តល់ឱ្យវិនិយោគិននៃភាគីជាប់កិច្ចសន្យាម្ខាងទៀតនូវផលប្រយោជន៍នៃប្រព្រឹត្តិកម្ម ភាពអនុគ្រោះ ឬបុព្វសិទ្ធិណាមួយដែលភាគីជាប់កិច្ចសន្យាពីមុនធ្លាប់បានផ្តល់ឱ្យដោយផ្អែកលើ :

ក- កិច្ចព្រមព្រៀងណាមួយដែលមានស្រាប់ ឬពេលអនាគត ស្តីពីសហពន្ធ័គយ ឬសហពន្ធ័សេដ្ឋកិច្ចតំបន់ពាណិជ្ជកម្មសេរី ឬកិច្ចព្រមព្រៀងអន្តរជាតិប្រហាក់ប្រហែលដែលភាគីជាប់កិច្ចសន្យាណាមួយស្ថិតនៅជាសមាជិក ឬអាចក្លាយជាសមាជិកនៅពេលខាងមុខ ។

ខ- កិច្ចព្រមព្រៀងអន្តរជាតិ ឬការរៀបចំរួលណាមួយដែលមានការពាក់ព័ន្ធទាំងស្រុង ឬមួយផ្នែកទៅនឹងបញ្ហាពន្ធដារ ។

## មាត្រានី ៥
## ការដកហូត

១- ភាគីជាប់កិច្ចសន្យាមិនត្រូវដកហូត ឬធ្វើជាតូបនីយកម្មដោយផ្ទាល់ ឬដោយប្រយោលលើការវិនិយោគរបស់វិនិយោគិននៃភាគីជាប់កិច្ចសន្យាផ្សេងទៀតនៅលើទឹកដីរបស់ខ្លួនឡើយ ឬប្រកាន់យកនូវវិធានការណាមួយ ឬគ្រប់វិធានការដែលមានសមមូល (ដែលចាប់ពីនេះតទៅហៅថាការដកហូត) លើកលែង :

ក- សំរាប់គោលបំណងជាផលប្រយោជន៍សាធារណៈ

ខ- លើមូលដ្ឋានគ្មានការរើសអើង

គ- ស្របទៅតាមនីតិវិធីនៃច្បាប់ និង

ឃ- ភ្ជាប់ជាមួយការទូទាត់សំណង យ៉ាងឆាប់រហ័ស គ្រប់ចំនួន និងជំងឺចិត្តដែលមាន ប្រសិទ្ធិភាព ។

២- សំណងបែបនេះត្រូវធ្វើការទូទាត់ដោយគ្មានការពន្យារពេល ។

៣- សំណងបែបនេះត្រូវមានទឹកប្រាក់ស្មើនឹងតំលៃទីផ្សារដ៏ត្រឹមត្រូវនៃតំលៃវិនិយោគដែលបានដកហូតមុនពេលដែលការដកហូតត្រូវបានកើតមានឡើង ។ តំលៃទីផ្សារដ៏ត្រឹមត្រូវនឹងមិនបង្ហាញពីការប្រែប្រួលតំលៃណាមួយឡើយ ព្រោះថាការដកហូតត្រូវដឹងជាសាធារណៈពីមុនរួចហើយ ។

៤- សំណងបែបនេះត្រូវបានអនុវត្តបានដោយពេញលេញ និងអាចផ្ទេរបានដោយសេរី ។

៥- វិនិយោគិននៃភាគីជាប់កិច្ចសន្យាដែលរងនូវការដកហូតដោយភាគីជាប់កិច្ចសន្យាម្ខាងទៀត មានសិទ្ធិដើម្បីពិនិត្យមើលភ្លាមៗនូវករណីរបស់ខ្លួន រួមមានការវាយតំលៃលើការវិនិយោគរបស់ខ្លួន និងការទូទាត់សំណងស្របទៅតាមបទបញ្ញត្តិនៃមាត្រានេះ ដោយអាជ្ញាធរ តុលាការ ឬអាជ្ញាធរមានសមត្ថកិច្ច និងឯករាជ្យផ្សេងទៀតនៃភាគីជាប់កិច្ចសន្យាដែលជាអ្នកដកហូត ។

## មាត្រាទី ៦

## សំណងសំរាប់ការខូចខាត ឬការបាត់បង់

១- នៅពេលដែលការវិនិយោគធ្វើឡើងដោយវិនិយោគិននៃភាគីណាមួយទទួលរងនូវការខាតបង់ ឬខូចខាតដែលបណ្តាលមកពីសង្គ្រាម ឬជំលោះអាវុធផ្សេងៗទៀត ភាពចលាចលស៊ីវិល បដិវត្ត កុប្បកម្ម ឬហេតុការណ៍ប្រហាក់ប្រហែលនៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ការវិនិយោគនោះត្រូវតែបានយល់ព្រមដោយភាគីជាប់កិច្ចសន្យា ដែលជាម្ចាស់ទឹកដីនោះនូវប្រព្រឹត្តិកិច្ចដូចជាការធ្វើអោយដូចដើមវិញ ការប៉ះប៉ូវសំណង ឬដំណោះស្រាយណាមួយផ្សេងទៀតដែលមានភាពអនុគ្រោះមិនតិចជាងអ្វីដែលបានផ្តល់ឱ្យវិនិយោគិនរបស់ខ្លួន ឬវិនិយោគិននៃរដ្ឋទីបីណាមួយឱ្យតែប្រព្រឹត្តកិច្ចនោះមានភាពអនុគ្រោះច្រើនសំរាប់វិនិយោគិនពាក់ពន្ធ័ ។ ទោះជាយ៉ាងនេះក៏ដោយការខាតបង់ដែលកើតចេញពីហានីភ័យធម្មតានៃអាជីវកម្ម នឹងមិនចាត់ទុកជាករណីត្រូវបានទទួលការទូទាត់សំណងទេ ។

២- ដោយមិនប៉ះពាល់ដល់វាក្យខណ្ឌទី ១ នៃមាត្រានេះ វិនិយោគិននៃភាគីជាប់កិច្ចសន្យាដែលស្ថិតនៅក្នុងហេតុការណ៍ណាមួយផ្អែកលើវាក្យខ័ណ្ឌនេះ បានរងការខូចខាត ឬការខាតបង់នៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតដែលបណ្តាលមកពី :

ក- ការរឹបអូសទ្រព្យសម្បត្តិ ឬផ្នែកខ្លះនៃទ្រព្យសម្បត្តិរបស់ខ្លួន ឬជាចំណែកនៃទ្រព្យសម្បត្តិ ដោយកំលាំងទ័ព ឬអាជ្ញាធរ ។

ខ- ការបំផ្លាញទ្រព្យសម្បត្តិរបស់ខ្លួនដោយកងកំលាំង ឬអាជ្ញាធរដែលមិនមែនជាមូលហេតុនៃការប្រយុទ្ធគ្នាឬដែលមិនស្ថិតក្នុងស្ថានភាពចាំបាច់ទេនោះ នឹងត្រូវទទួលបាននូវការធ្វើអោយដូចដើមវិញភ្លាមៗ ហើយការទូទាត់សំណងសំរាប់ការខូចខាត ឬការខាតបង់ត្រូវឆាប់រហ័សគ្រប់ចំនួន និងជាក់ស្តែងនៅទីកន្លែងដែលមានការរឹបអូស ឬការបំផ្លាញនោះ ។ ការទូទាត់ត្រូវធ្វើដោយរូបិយបណ្ណ័ដែលអាចប្តូរបានដោយសេរី និងពុំមានការពន្យារពេលឡើយ ។

## មាត្រានី ៧
## ការផ្ទេរ

១- ភាគីនិមួយៗត្រូវអនុញ្ញាតថា រាល់ការទូទាត់ទាក់ទងទៅនឹងការវិនិយោគក្នុងទឹកដីរបស់ខ្លួននៃវិនិយោគិនរបស់ភាគីជាប់កិច្ចសន្យាម្ខាងទៀត អាចផ្ទេរដោយសេរីនៅក្នុង ឬទៅខាងក្រៅទឹកដីរបស់ខ្លួនដោយគ្មានការពន្យារពេល ។ ទោះបីជាមិនដាច់ខាតក្តី ការផ្ទេរនេះរាប់បញ្ចូលជាពិសេសនូវ :

ក- ដើមទុនដំបូង និងទឹកប្រាក់បន្ថែមដើម្បីទ្រទ្រង់ ឬពង្រីកវិនិយោគ

ខ- ផលចំណូលដូចបានផ្តល់និយមន័យក្នុងវាក្យខ័ណ្ឌ ២ នៃមាត្រា (១) នៃកិច្ចព្រមព្រៀងនេះ

គ- ការទូទាត់សងដែលចែងក្នុងកិច្ចសន្យា រួមមានកិច្ចព្រមព្រៀងខ្ចីប្រាក់ទាក់ទងនឹងការវិនិយោគ

ឃ- ប្រាក់ដែលបានមកពីការលក់ ឬការជំរះបញ្ជីនៃការវិនិយោគទាំងអស់ ឬមួយផ្នែក

ង- ការទូទាត់ដែលបានមកពីការទូទាត់សំណងដូចមានចែងក្នុងមាត្រា (៥) (៦) និង (៨) នៃកិច្ចព្រមព្រៀងនេះ

ច- ការទូទាត់ដែលបានមកពីការដោះស្រាយលើករណីជំលោះវិនិយោគ

ឆ- ចំណូលឬប្រាក់បំណាច់នៃបុគ្គលិកមកពីបរទេសដែលបំរើការងារទាក់ទងនឹងការវិនិយោគ ស្របតាមមាត្រា (២) នៃកិច្ចព្រមព្រៀងនេះ ។

២- ភាគីនីមួយៗត្រូវធានាថា ការផ្ទេរដែលមានចែងក្នុងវាក្យខ័ណ្ឌ ១ នៃមាត្រានេះត្រូវធ្វើដោយរូបិយវត្ថុដែលអាចប្ដូរបានដោយសេរីទៅតាមអត្រាជាទូទៅ នៃការប្ដូរប្រាក់ដែលកំណត់ដោយអ្នកធ្វើអាជីវកម្មមានច្បាប់ ហើយដែលមានសុពលភាពក្នុងថ្ងៃផ្ទេរនៅក្នុងទឹកដីនៃភាគីដែលមានការវិនិយោគ ។

៣- ភាគីនីមួយៗត្រូវធានាថា ការប្រាក់ "ប្រសិនជាមាន" នៅក្នុងការទូទាត់ ការប៉ះប៉ូវសំណងដែលបានអូសបន្លាយពេលឬមិនបានអនុវត្តក្រោយថ្ងៃកំណត់សំរាប់ការទូទាត់ ត្រូវធ្វើការគណនាជាមួយគ្នានឹងការប៉ះប៉ូវសំណង សំរាប់រយៈពេលដែលគិតចាប់ផ្ដើមពីការកើតមាននៃបញ្ហា ដូចមានចែងក្នុងមាត្រា (៥) (៦) និង(៨) រហូតដល់ថ្ងៃដែលការផ្ទេរសំណង ហើយការទូទាត់នេះ នឹងមានប្រសិទ្ធិភាពអនុវត្តស្របតាមបទបញ្ញត្តិនៃវាក្យខ័ណ្ឌ ១ និង ២ នៃមាត្រានេះ ។

## មាត្រានី ៨
## ឧបត្ថម្ភ

ក្នុងករណីដែលភាគីជាប់កិច្ចសន្យាមួយ ឬភ្នាក់ងារដែលបានតែងតាំងបានផ្ដល់នូវការទូទាត់ក្រោមរូបភាពជាសំណងការធានាឬកិច្ចសន្យាធានារ៉ាប់រង ដើម្បីទប់ទល់ជាមួយហានិភ័យមិនមែនពាណិជ្ជកម្មទាក់ទងនឹងការវិនិយោគរបស់វិនិយោគិនរបស់ខ្លួននៅលើទឹកដីនៃភាគីជាប់កិច្ចសន្យាខាងទៀតភាគីជាប់កិច្ចសន្យានោះ ត្រូវទទួលស្គាល់ការផ្ទេរសិទ្ធិ ឬការទាមទារនៃវិនិយោគិននៃភាគីជាប់កិច្ចសន្យាមុន ឬភ្នាក់ងារដែលបានតែងតាំង និងសិទ្ធិនៃភាគីជាប់កិច្ចសន្យាមុននោះឬភ្នាក់ងារដែលបានតែងតាំង ដើម្បីប្រតិបត្តិកិច្ចការដោយយោងទៅលើឧបទេសកម្មនៃសិទ្ធិនោះ និងការទាមទារដែលមានវិសាលភាពដូចគ្នានឹងអ្នកផ្ដល់សិទ្ធិអនុវត្តផ្ទាល់ដែរ ។

## មាត្រានី ៩
## ការអនុវត្តន៍បណ្ដាបទបញ្ញត្តិផ្សេងៗ

ប្រសិនបើបណ្តាបទបញ្ញត្តិនៃច្បាប់របស់ភាគីជាប់កិច្ចសន្យាណាមួយ ឬកាតព្វកិច្ចនៃច្បាប់អន្តរជាតិ ដែលមាននាពេលបច្ចុប្បន្នឬបានបង្កើតឡើងក្រោយមករវាងភាគីជាប់កិច្ចសន្យា ដើម្បីបំពេញបន្ថែមលើកិច្ចព្រមព្រៀងបច្ចុប្បន្ន ហើយបានចែងនូវបទបញ្ញត្តិមានលក្ខណៈទូទៅឬពិសេស ផ្តល់សិទ្ធិដល់ការវិនិយោគដែលបានធ្វើឡើងដោយវិនិយោគិននៃភាគីជាប់កិច្ចសន្យាម្ខាងទៀតនូវប្រព្រឹត្តកម្ម ដែលមានអំណោយផលជាងអ្វីដែលបានផ្តល់ដោយកិច្ចព្រមព្រៀងបច្ចុប្បន្ន បទបញ្ញត្តិដែលមានភាពអនុគ្រោះជាងនោះនឹងមានអនុភាពអនុវត្តលើកិច្ចព្រមព្រៀងបច្ចុប្បន្ន ។

## មាត្រានី ១០
## ដំណោះស្រាយវិវាទរវាងភាគីជាប់កិច្ចសន្យា និងវិនិយោគិន នៃភាគីជាប់កិច្ចសន្យាម្ខាងទៀត

១- វិវាទណាមួយដែលកើតឡើងដោយផ្ទាល់ពីសំណាក់ការវិនិយោគរវាងភាគីជាប់កិច្ចសន្យាមួយជាមួយវិនិយោគិននៃភាគីជាប់កិច្ចសន្យាម្ខាងទៀត នឹងត្រូវដោះស្រាយដោយមិត្តភាពរវាងភាគីពាក់ព័ន្ធ ។

២- ប្រសិនបើវិវាទមិនអាចដោះស្រាយបានក្នុងរយៈពេលប្រាំមួយ(៦)ខែ ចាប់ពីថ្ងៃដែលករណីវិវាទត្រូវបានលើកឡើងជាលាយល័ក្ខអក្សរ វិវាទនោះនឹងត្រូវជ្រើសរើសដោយវិនិយោគិនដើម្បីស្នើបញ្ជូនទៅ :

ក- តុលាការមានសមត្ថកិច្ចនៃភាគីជាប់កិច្ចសន្យាក្នុងទឹកដីដែលការវិនិយោគបានធ្វើឡើងឬ

ខ- តុលាការអាជ្ញាកណ្តាល អាត់-ហុក ដែលជាតុលាការនឹងត្រូវបង្កើតឡើងក្រោមវិធានមជ្ឈត្តវិនិច្ឆ័យនៃគណៈកម្មការសហប្រជាជាតិស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ (UNCITRAL) លើកលែងតែមានការយល់ព្រមខុសពីនេះដោយភាគីវិវាទ ។ អាចជាករណីមិនមានការគាំជាស្វ័យប្រវត្តិទៅមជ្ឈត្តវិនិច្ឆ័យអន្តរជាតិទេ លើកលែងតែភាគីជាប់កិច្ចសន្យា ឬភ្នាក់ងាររបស់ភាគីនោះ ឬអន្តរការីដែលមានការពាក់ព័ន្ធបានធ្វើការបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀងជាមួយវិនិយោគិន ។

៣- កិច្ចព្រមព្រៀងដោះស្រាយវិវាទរវាងភាគីជាប់កិច្ចសន្យាម្ខាងជាមួយវិនិយោគិន នៃភាគីជាប់កិច្ចសន្យាម្ខាងទៀត នឹងមានសិទ្ធិគ្របដណ្តប់កិច្ចព្រមព្រៀងនេះ និងវិធីនៃការដោះស្រាយជំលោះ

ប្រសិនបើមាន ដែលបានកំណត់ក្នុងនោះ នឹងពុំរូវឱ្យភាគីទាំងពីរអនុវត្តដោយមិនគិតពីកិច្ចព្រមព្រៀងនេះឡើយ ។

៤- វិនិយោគិនដែលបានដាក់ជូនជំលោះទៅជូនតុលាការជាតិ មិនអាចមានសិទ្ធិប្តឹងតវ៉ាទៅតុលាការអាជ្ញាកណ្តាលណាមួយដូចមានបញ្ជាក់នៅក្នុងវាក្យខ័ណ្ឌ ២ (ខ) និង (៣) នៃមាត្រានេះទេ ។

៥- គ្មានភាគីជាប់កិច្ចសន្យាណាមួយដែលជាភាគីវិវាទអាចលើកឡើងនូវការជំទាស់ទៅតាមដំណាក់កាលណាមួយនៃនីតិវិធីមជ្ឈត្តវិនិច្ឆ័យឬការដាក់ឱ្យអនុវត្តនូវសេចក្តីសំរេចរបស់អាជ្ញាកណ្តាលបានទេដោយហេតុថា វិនិយោគិនដែលជាភាគីជំលោះម្ខាងទៀតបានទទួលនូវសំណងដែលអាចជាចំណែក ឬទាំងអស់នៃការខាតបង់របស់ខ្លួនអាស្រ័យដោយមានការទទួលធានារ៉ាប់រង ។

៦- ការសំរេចរបស់មជ្ឈត្តករគឺជាការសំរេចចុងក្រោយ ហើយដែលភាគីជំលោះទាំងពីរត្រូវតែគោរព ។ ការសំរេចនោះត្រូវបានអនុវត្តស្របទៅតាមច្បាប់ជាតិ ។

៧- នៅក្នុងវិវាទរវាងវិនិយោគិនជាមួយភាគីជាប់កិច្ចសន្យា ច្បាប់នៃភាគីជាប់កិច្ចសន្យានឹងគ្រប់គ្រងលើការដោះស្រាយវិវាទនោះ ។

៨- ច្បាប់ដែលដាក់កំហិតរបស់ប្រទេសម្ចាស់ផ្ទះ នឹងត្រូវអនុវត្តចំពោះរាល់ការតវ៉ា ឬសំណើដែលធ្វើឡើងដោយវិនិយោគិនដើម្បីដាក់ទៅមជ្ឈត្តវិនិច្ឆ័យលើកលែងតែកន្លែងណាដែលវិធាននៃច្បាប់មជ្ឈត្តវិនិច្ឆ័យពាក់ព័ន្ធនោះផ្តល់នូវរយៈពេលខ្លីនៃការកំណត់ខ័ណ្ឌសីមាដែលវិធានសំរាប់ករណីនោះ នឹងត្រូវអនុវត្តទៅបាន ។

## មាត្រានី ១១

## ការដោះស្រាយវិវាទរវាងភាគីជាប់កិច្ចសន្យា

១- វិវាទរវាងភាគីជាប់កិច្ចសន្យាដែលទាក់ទងដល់ការបកស្រាយ ឬការអនុវត្តនីកិច្ចព្រមព្រៀងនេះ នឹងត្រូវដោះស្រាយតាមការចរចាទៅតាមលទ្ធភាពដែលអាចធ្វើបាន ។

២- ប្រសិនបើវិវាទមិនអាចដោះស្រាយបានតាមវាក្យខ័ណ្ឌទី ១ នៃមាត្រានេះក្នុងរយៈពេលប្រាំមួយ (៦) ខែទេនោះ វិវាទនោះត្រូវស្នើឡើងដោយភាគីជាប់កិច្ចសន្យាណាមួយទៅតុលាការអាជ្ញាកណ្តាល ។

៣- តុលាការអាជ្ញាកណ្តាលនោះត្រូវបានបង្កើតឡើងទៅតាមករណី អាត់-ហុក តាមបែបបទដូចតទៅ : ភាគីជាប់កិច្ចសន្យានិមួយៗ ត្រូវតែងតាំងអាជ្ញាកណ្តាលរបស់ខ្លួនម្នាក់ទៅក្នុងតុលាការអាជ្ញាកណ្តាលនោះ បន្ទាប់មកអាជ្ញាកណ្តាលទាំងពីរនេះត្រូវជ្រើសរើសជនជាតិម្នាក់នៃរដ្ឋទី ៣ ដើម្បីធ្វើជាប្រធានតុលាការអាជ្ញាកណ្តាល ។ អាជ្ញាកណ្តាលទាំងនេះ ត្រូវតែងតាំងអោយស្រេចក្នុងរយៈពេលពីរ (២) ខែ គិតពីថ្ងៃដែលភាគីជាប់កិច្ចសន្យាម្ខាងបានជូនដំណឹងទៅភាគីម្ខាងទៀត នូវគោលបំណងក្នុងការដាក់វិវាទនោះទៅតុលាការអាជ្ញាកណ្តាល ហើយប្រធានតុលាការអាជ្ញាកណ្តាលត្រូវបានតែងតាំងក្នុងរយៈពេលពីរ (២) ខែបន្ទាប់ ។

៤- ប្រសិនបើក្នុងរយៈពេលដែលបានកំណត់ក្នុងវាក្យខ័ណ្ឌទី ៣ នៃមាត្រានេះ មិនអាចធ្វើបានបើគ្មានការសំរួមសំរួលណាទៀតទេនោះ ភាគីជាប់កិច្ចសន្យាណាមួយអាចអញ្ជើញប្រធានតុលាការយុត្តិធម៌អន្តរជាតិដើម្បីធ្វើការតែងតាំងជាចាំបាច់នេះ ។ ប្រសិនបើប្រធានតុលាការនោះជាជនជាតិនៃភាគីជាប់កិច្ចសន្យាណាមួយ ឬមិនអាចបំពេញមុខងារនេះបាន អនុប្រធានតុលាការនឹងត្រូវបានតែងតាំងជាប្រធានតុលាការ ឬក្នុងករណីដែលអនុប្រធានមិនមានសមត្ថភាព សមាជិករបស់តុលាការយុត្តិធម៌អន្តរជាតិដែលមានឋានៈ បន្ទាប់នឹងត្រូវបានអញ្ជើញ ដើម្បីធ្វើការតែងតាំងនេះដោយស្ថិតនៅក្រោមលក្ខខ័ណ្ឌដូចគ្នា ។

៥- តុលាការអាជ្ញាកណ្តាល ត្រូវកំណត់នូវនីតិវិធីការងារសំរាប់ដំណើរការរបស់ខ្លួន ។ ទីកន្លែងសំរាប់ដំណើរការធ្វើសេចក្តីវិនិច្ឆ័យ នឹងត្រូវកំណត់ដោយភាគីជាប់កិច្ចសន្យា ។

៦- តុលាការអាជ្ញាកណ្តាល ត្រូវធ្វើការសំរេចក្តីដោយយោងទៅតាមបទបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ និងផ្អែកទៅតាមវិធាននៃច្បាប់អន្តរជាតិ ។ ការសំរេចក្តីត្រូវធ្វើឡើងតាមរយៈការបោះឆ្នោតយកសំឡេងភាគច្រើន ។ ការសំរេចក្តីនោះ គឺជាការសំរេចចុងក្រោយ ហើយដែលភាគីជំលោះត្រូវតែគោរពតាម ។

៧- ភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវទទួលរ៉ាប់រងចេញនូវសោហ៊ុយចំណាយសំរាប់អាជ្ញាកណ្តាលរបស់ខ្លួន និង សំរាប់អ្នកតំណាងស្របច្បាប់របស់ខ្លួន ក្នុងដំណើរការដំណោះស្រាយវិវាទរបស់អាជ្ញាកណ្តាល ។ តម្លៃចំណាយសំរាប់ប្រធានតុលាការ និងចំណាយដែលនៅសេសសល់ទៀត ត្រូវតែជាបន្ទុកដែលភាគីទាំងពីរត្រូវទទួលចេញដោយស្មើគ្នា ។ ទោះជាយ៉ាងណាក៏ដោយតុលាការអាចធ្វើការសំរេចក្តីឱ្យធ្វើការបែងចែកការចំណាយតាមរូបភាពផ្សេងទៀត ។

## មាត្រានី ១២
## ការអនុវត្តនៃកិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងនេះ មានប្រសិទ្ធភាពអនុវត្តសំរាប់ការវិនិយោគដែលធ្វើ មុន ឬក្រោយការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ប៉ុន្តែមិនអនុវត្តសំរាប់វិវាទវិនិយោគដែលបានកើតឡើងមុនការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះឡើយ ។

## មាត្រានី ១៣
## ការចូលជាធរមាន

កិច្ចព្រមព្រៀងនេះ នឹងចូលជាធរមាននៅថ្ងៃដែលទទួលបាននូវការជូនដំណឹងចុងក្រោយពីភាគីទាំងពីរតាមផ្លូវទូត ដោយភាគីជាប់កិច្ចសន្យាម្ខាងជូនដំណឹងទៅភាគីជាប់កិច្ចសន្យាម្ខាងទៀតថា តំរូវការផ្នែកច្បាប់ក្នុងប្រទេសសំរាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងបានបំពេញរួចរាល់ហើយ ។

## មាត្រានី ១៤
## រយៈពេល និងការបញ្ចប់

១- កិច្ចព្រមព្រៀងនេះមានសុពលភាពអនុវត្តរយៈពេលដប់ (១០)ឆ្នាំ ហើយត្រូវនៅបន្តមានសុពលភាពសំរាប់រយៈពេលដប់ (១០)ឆ្នាំទៀត លើកលែងតែមួយឆ្នាំមុនពេលផុតកំណត់នៃថិរវេលាដំបូង ឬរយៈពេលបន្តបន្ទាប់ ភាគីជាប់កិច្ចសន្យាម្ខាងបានជូនដំណឹងទៅភាគីជាប់កិច្ចសន្យាម្ខាងទៀតនូវគោលបំណងស្តីពីការបញ្ចប់កិច្ចព្រមព្រៀងនេះ ។ ក្នុងករណីនេះ សេចក្តីជូនដំណឹងពីការបញ្ចប់នឹងមានប្រសិទ្ធភាពចាប់ពីពេលផុតកំណត់នៃរយៈពេល ដប់ (១០)ឆ្នាំនេះ ។

២- ចំពោះការវិនិយោគដែលបានធ្វើមុនថ្ងៃ ការជូនដំណឹងពីការបញ្ចប់កិច្ចព្រមព្រៀងចូលជាធរមាន បណ្តាបទបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ត្រូវស្ថិតនៅមានប្រសិទ្ធិភាព និងអនុវត្តបន្តសំរាប់រយៈពេល ដប់ (១០)ឆ្នាំទៀត ដោយចាប់គិតពីថ្ងៃបញ្ចប់កិច្ចព្រមព្រៀងនេះ ។

ដើម្បីជាសក្ខីភាពកិច្ចព្រមព្រៀងនេះ អ្នកតំណាងស្របច្បាប់ដែលបានទទួលការអនុញ្ញាតពីរដ្ឋាភិបាលរៀងៗខ្លួនមានសិទ្ធិគ្រប់គ្រាន់ក្នុងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។

កិច្ចព្រមព្រៀងនេះធ្វើនៅភ្នំពេញ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៤ ចំនួនជា ២ ច្បាប់ដើម ជាភាសាខ្មែរ និងអង់គ្លេស ហើយអត្ថបទទាំងអស់មានតំលៃដូចគ្នា ។ ក្នុងករណីមានការបកស្រាយផ្សេងគ្នា អត្ថបទជាភាសាអង់គ្លេស ត្រូវបានយកជាសំអាង ។

**តំណាងរដ្ឋាភិបាលនៃ**
**ព្រះរាជាណាចក្រកម្ពុជា**

ចម ប្រសិទ្ធ
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**តំណាងរដ្ឋាភិបាលនៃ**
**សាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន**

បណ្ឌិត អាប់ឌុល ហាហ្វ៊ី ស្ហេក
**រដ្ឋមន្ត្រីឯកជនភាវូបនីយកម្ម**

# AGREEMENT BETWEEN THE GOVERNMENT OF THE KINGDOM OF CAMBODIA AND THE GOVERNMENT OF THE ISLAMIC REPUBLIC OF PAKISTAN ON THE PROMOTION AND PROTECTION OF INVESTMENT

The Government of the Kingdom of Cambodia and the Government of the Islamic Republic of Pakistan hereinafter referred to as the "Contracting Parties";

**Desiring** to create favorable condition for greater economic cooperation between them and in particular for investments by investors of one State in the territory of the other State based on the principles of equality and mutual benefit;

**Recognizing** that the encouragement and reciprocal protection of such investments will be conducive to stimulating business initiative and increasing prosperity in both States;

**Agreeing** that a stable framework for investment will maximize effective utilization of economic resources and foster economic prosperity;

**Having** resolved to conclude the Agreement on the Promotion and Reciprocal Protection of Investments;

Have agreed as follows:

## ARTICLE 1
## DEFINITIONS

For the purposes of this Agreement:

1. The term "investment" means;

   a) "the assets or money invested in connection with economic activities connected with business by an investor of one Contracting Party in the territory of the other Contracting Party for setting up, establishment or control of Industry, undertaking or establishment engaged in the production, distribution or processing of any goods or the development and extraction of such mineral resources and products as may be specified in this behalf by the Contracting Party."

   b) "The term "investment "does not include contracts to provide a service and the construction contracts. "

   c) "In case of contract (s) between the resident of one Party and the resident of the other party, the terms and conditions of the contract (s) signed between them will over-ride the clauses of this agreement and will be governed by the terms and conditions of that contract(s)."

   d) "The time bound contract (s) will not be treated as investment."

2. The term "returns" means monetary returns yielded by an investment including any profits, interest, capital gains, dividends, royalties or fees.

3. The term "Investor" means in respect of either Contracting Party:

   a) a natural person, a national of a Contracting Party who makes an investment in the territory of the other Contracting Party;

   b) a legal person incorporated, constituted or, otherwise duly organised in accordance with the laws and regulations of one Contracting Party, having its seat and performing real business activity in the territory of the same Contracting Party

and making an investment in the territory of the other Contracting Party.

4. The term "freely convertible currency" means any currency that is widely used to make payments for international transactions and widely traded in the principal international exchange markets.

5. The term "territory" means:

(a) in respect of the Kingdom of Cambodia, the territory over which the Kingdom of Cambodia has sovereignty or jurisdiction.

(b) in respect of the Islamic Republic of Pakistan, the territories as defined in Article 1 (2) of the Constitution of Islamic Republic of Pakistan.

## ARTICLE 2
## PROMOTION AND PROTECTION OF INVESTMENTS

1. Each Contracting Party shall encourage and create favourable conditions for investors of the other Contracting Party to make investments in its territory and shall admit such investments in accordance with its laws and regulations.

2. In order to encourage mutual investment flows, each Contracting Party shall endeavour to inform the other Contracting Party, at the request of that other Contracting Party, on the investment opportunities in its territory.

3. Each Contracting Party shall consider in good faith whenever necessary in accordance with its laws and regulations without delay the request for permits required in connection with the activities of consultants or experts engaged by investors of the other Contracting Party.

4. Each Contracting Party shall subject to its laws, regulations and procedures affecting the entry stay and work of natural persons, examine in good faith and give consideration to request of key personnel ( nationals of the contracting parties) including top managerial and technical persons who are employed for the purposes of investments in its territory to enter, remain temporarily and work in its territory. Immediate family members (spouse and minor children) of such key personnel shall also be granted similar treatment with regard to the entry and temporary stay in the host Contracting Party.

## ARTICLE 3
## PROTECTION OF INVESTMENTS

1. Each Contracting Party shall extend in its territory full protection and security to investments and returns of investors of the other Contracting Party. Neither Contracting Party shall impair by arbitrary or discriminatory measures, the development, management, maintenance, use, enjoyment, expansion, sale and if it is the case, the liquidation of such investments. A Contracting Party shall observe any other obligation it may have entered into with regard to investments of investors of the other Contracting Party.

2. Investments or returns of investors of a Contracting Party in the territory of the other Contracting Party shall be accorded fair and equitable treatment in accordance with the laws and regulations of the latter Contracting Party and the provisions of this Agreement.

## ARTICLE 4
## NATIONAL TREATMENT AND MOST FAVOURED NATION TREATMENT

1. Each Contracting Party shall accord in its territory to investments and returns of investors of the other Contracting Party a treatment no less favourable than that which it accords to investments and returns of its own investors, or investments and returns of investors of any other third State, whichever is more favourable to the investors concerned.

2. Contracting Party shall accord in its territory to investors of the other Contracting Party, as regards management, maintenance, employment, use or disposal of their investment, a treatment which is no less favourable than that which it accords to the investors of any third State.

3. The provisions of paragraph 1 and 2 of this Article shall not be construed so as to oblige one Contracting Party to extend to the investors of the other Contracting Party the benefit of any treatment, preference or privilege, which may be extended by the former Contracting Party by virtue of:

a) any existing or future customs union or economic union, free trade area or similar international agreements to which either of the Contracting Party is or may become a party in the future;

b) any international agreement or arrangement, completely or partially related to taxation,

## ARTICLE 5
## EXPROPRIATION

1. A Contracting Party shall not expropriate or nationalise, directly or indirectly, an investment in its territory of an investor of the other Contracting Party or take any measure or measures having equivalent effect (hereinafter referred to as "expropriation") except:

a) for a purpose which is in the public interest;

b) on a non-discriminatory basis;

c) in accordance with due process of law; and

d) accompanied by payment of prompt, adequate and effective compensation.

2. Such compensation shall be paid without delay.

3. Such compensation shall be equivalent to the fair market value of the expropriated investment immediately before the expropriation occurred. The fair market value shall not reflect any change in value occurring because the expropriation had become publicly known earlier.

4. Such compensation shall be fully realizable and freely transferable.

5. An investor of a Contracting Party affected by the expropriation carried out by the other Contracting Party shall have the right to prompt review of its case including the valuation of its investments and the payment of compensation in accordance with the provisions of this Article by a judicial authority or other competent and independent authority of the latter Contracting Party.

## ARTICLE 6
## COMPENSATION FOR DAMAGE OR LOSS

1. When investments made by investors of either Contracting Party suffer loss or damage owing to war or other armed conflict, civil disturbances, revolution, riot or similar events in the territory of the other Contracting Party, they shall be accorded by the latter Contracting Party, treatment, as regards restitution, indemnification, compensation or any other settlement, not less favourable than that accorded by the latter Contracting Party to its own investors or to investors of any third State, whichever is more favourable to the investors concerned. However, the losses which are covered under normal business risks, will not qualify for payment of compensation on this account.

2. Without prejudice to paragraph 1 of this Article, investors of one Contracting Party who in any of the events referred to in that paragraph suffer damage or loss in the territory of the other Contracting Party resulting from:

a) requisitioning of their property or part thereof by its forces or authorities;

b) destruction of their property by its force or authorities, which was not caused in combat action or was not required by the necessity of the situation, shall be accorded a prompt restitution, and where applicable prompt, adequate and effective compensation for damage or loss, sustained during the period of requisitioning or as a result of destruction of the property. Resulting payments shall be made in freely convertible currency without delay.

## ARTICLE 7
## TRANSFERS

1. Each Contracting Party shall permit that all payments relating to an investment in its territory of an investor of the other Contracting Party may be freely transferred into and out of its territory without delay. Such transfers shall include in particular, though not exclusively:

a) the initial capital and additional amounts to maintain or increase an investment;

b) returns as defined in paragraph 2 of Article 1 of this Agreement;

c) payments made under contract including a loan agreement relating to the investment;

d) proceeds from the sale or liquidation of all or any part of investments;

e) payments of compensation under Articles 5, 6 and 8 of this Agreement;

f) payments arising out of the settlement of an investment dispute;

g) earnings and other remuneration of personnel engaged from abroad in connection with an investment in accordance with Article 2 of this Agreement.

2. Each Contracting Party shall ensure that the transfers under paragraph 1 of this Article are made in a freely convertible currency at the prevailing rate of exchange quoted by Authorised Dealers valid on the date of transfer in the territory of the Contracting Party in which the Investment is made.

3. Each Contracting Party shall ensure that the interest, if any, on the payments compensation delayed or not made after the date fixed for payment is calculated together with compensation for the period starting with the occurrence of events under Articles 5, 6 and 8 until the date of transfer of payment and payment will be effected in accordance with the provisions of paragraph 1 and 2 of this Article.

## ARTICLE 8
## SUBROGATION

If a Contracting Party or its designated agency makes a payment under an indemnity, guarantee or contract of insurance against non-commercial risks given in respect of an investment of an investor in the territory of the other Contracting Party, the latter Contracting Party shall recognize the assignment of any right or claim of such investor to the former Contracting Party or its designated agency and the right of the former Contracting Party or its designated agency to exercise by virtue of subrogation any such right and claim to the same extent as its predecessor in title.

## ARTICLE 9
## APPLICATION OF OTHER LEGAL PROVISIONS

If the provisions of law of either Contracting Party or international obligations existing at present or established thereafter between the Contracting Parties, in addition to the present Agreement, contain a rule, whether general or specific, entitling investments by investors of the other Contracting Party to a treatment more favourable than is provided for by the present Agreement, such rule shall, to the extent that, it is more favourable, prevail over the present Agreement.

## ARTICLE 10
## SETTLEMENT OF DISPUTES BETWEEN A CONTRACTING PARTY AND AN INVESTOR OF THE OTHER CONTRACTING PARTY

1. Any investment dispute arising directly from an investment between one Contracting Party and an investor of the other Contracting Party should be settled amicably between the two parties concerned.

2. If a dispute has not been settled within six ( 6 ) months from the date on which it was raised in writing, the dispute may, at the choice of investor, be submitted:

   a) to the competent courts of the Contracting Party in whose territory the investment is made; or

   b) to any ad hoc arbitration tribunal which unless otherwise agreed on by the parties to the dispute, is to be established under the Arbitration Rules of the United Nations Commission on International Trade Law (UNCITRAL), provided that there can be no automatic recourse to such international arbitration unless the Contracting Party or its agency or its instrumentality concerned specification in its agreement with an investor.

3. An Agreement to settle the dispute between one Contracting Party and an investor of the other Contracting Party will override this Agreement and the mode of dispute settlement, if any, provided therein shall bind the Parties irrespective of this Agreement.

4. An investor who has submitted the dispute to a national court cannot have recourse to one of the arbitral tribunals mentioned in paragraph 2(b) and (3) of this Article.

5. Neither of the Contracting Party, which is a party to a dispute can raise an objection, at any phase of the arbitration procedure or of the execution of an arbitral award, on account of the fact that the investor, which is the other party to the dispute, has received an indemnification covering a part or the whole of its losses by virtue of an insurance.

6. The award shall be final and binding on the parties to the dispute and shall be enforced in accordance with national law.

7. In dispute between an investor and a Contracting Party, the law of the Contracting Party will govern the resolution of such disputes.

8. The law of limitation of the host country will be applicable to any claim or request made for arbitration by the investor except where the relevant arbitration rules provide for a shorter period of limitation in which case those rules will apply.

## ARTICLE 11
## SETTLEMENT OF DISPUTES BETWEEN THE CONTRACTING PARTIES

1. Disputes between the Contracting Parties concerning the interpretation or application of this Agreement shall be settled as far as possible by negotiations.

2. If a dispute cannot be settled under paragraph 1 of this Article within six (6) months, it shall upon the request of either Contracting Party be submitted to an arbitral tribunal.

3. Such arbitral tribunal shall be constituted ad hoc as follows: each Contracting Party shall appoint one arbitrator and these two arbitrators shall agree upon a national of a third State as their chairman. Such arbitrators shall be appointed within two (2) months from the date one Contracting Party has informed the other Contracting Party of its intention to submit the dispute to an arbitral tribunal, the Chairman of which shall be appointed within two (2) further months.

4. If the periods specified in paragraph 3 of this Article are not observed, either Contracting Party may, in the absence of any other relevant arrangement, invite the President of the International Court of Justice to make the necessary appointments. If the president of the International Court of Justice is a national of either of the Contracting Parties, or if he is otherwise prevented from discharging the said function, the Vice-President or in case of his inability, the member of the International Court of Justice next in seniority shall be invited under the same conditions to make the necessary appointments.

5. The arbitral tribunal shall determine its own procedure. The place of arbitration proceedings shall be determined by the Contracting Parties.

6. The arbitral tribunal shall make its award in accordance with the provision of this Agreement and pursuant to the rules of international law. It shall make its award by a majority of votes. The award shall be final and binding.

7. Each Contracting Party shall bear the costs of its own arbitrator and of its legal representation in the arbitration proceedings. The costs of the Chairman and the remaining costs shall be borne in equal parts by both Contracting Parties. The tribunal may, however, in its award determine another distribution of costs.

## ARTICLE 12
## APPLICATION OF THE AGREEMENT

This Agreement shall apply to investments made prior to or after the entry into force of this Agreement, but shall not apply to any investment dispute that may have arisen before its entry into force.

## ARTICLE 13
## ENTRY INTO FORCE

This Agreement shall enter into force on the date of receipt of the last of the two notifications through diplomatic channels by which either Contracting Party notifies the other Contracting Party that its internal legal requirements for the entry into force of this Agreement have been fulfilled.

## ARTICLE 14
## DURATION AND TERMINATION

1. This Agreement shall remain in force for a period of ten (10) years and shall be extended thereafter for the following ten (10) year periods unless, one year before the expiration of the initial or any subsequent period, one Contracting Party notifies the other Contracting Party of its intention to denounce the Agreement. In that case, the notice of denunciation shall become effective by the expiration of the current period of ten (10) years.

2. In respect of investments made prior to the date when the notice of termination of this Agreement become effective the provisions of this Agreement shall continue to be effective and applicable for a period of ten (10) years from the date of termination of this Agreement.

IN WITNESS WHEREOF, the undersigned representatives, duly authorised thereto, have signed the present Agreement.

DONE at Phnom Penh, on 27th April 2004, in two originals, each in the Khmer, and English languages, all texts being equally authentic. The text in the English language shall prevail in case of difference of interpretation.

| FOR THE GOVERNMENT OF THE KINGDOM OF CAMBODIA | FOR THE GOVERNMENT OF THE ISLAMIC REPUBLIC OF PAKISTAN |
| --- | --- |
| CHAM PRASIDH | Dr. ABDUL HAFEEZ SHEIKH |
| Minister of Commerce | Minister of Privatisation |